


សម្ព័ន្ធខ្មែរជំរឿន
និងការពារសិទ្ធិមនុស្ស
លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE
PROMOTION AND DEFENSE
OF
HUMAN RIGHTS


# ពេលដែលត្រូវដោះលែងឱ្យនៅក្រៅឃុំ៖

## បញ្ឈប់ការឃុំខ្លួនបណ្ដោះអាសន្នមិនចាំបាច់


របាយការណ៍សង្ខេប
ចេញផ្សាយ ខែតុលា ឆ្នាំ២០១៨

# ពេលដែលត្រូវដោះលែងឱ្យនៅក្រៅឃុំ៖

## បញ្ឈប់ការឃុំខ្លួនបណ្ដោះអាសន្នមិនចាំបាច់

របាយការណ៍សង្ខេបចេញផ្សាយ ខែតុលា ឆ្នាំ២០១៨

**សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ**

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស
# (លីកាដូ)

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការដែលស្ថិតនៅជួរមុខគេ ក្នុងកិច្ចការពារសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច និងសិទ្ធិសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជា និងលើកកម្ពស់ ការគោរពសិទ្ធិទាំងនេះពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា និងអង្គការនានា។ ដោយបានកសាងនូវសមិទ្ធិផលល្អក្នុងអតីតកាល លីកាដូ បានបន្តដើរតួនាទីជាអ្នកតស៊ូមតិសម្រាប់ប្រជាពលរដ្ឋ និងធ្វើការឃ្លាំមើលស្ថានភាពសង្គមតាមរយៈកម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស ពីការិយាល័យកណ្តាលរបស់ខ្លួននៅរាជធានីភ្នំពេញ និងនៅតាមសាខាទាំង ១៣ ខេត្តផ្សេងទៀត។

## កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស

### ឃ្លាំមើលការរំលោភសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ

បុគ្គលិកអង្គការលីកាដូ ធ្វើការឃ្លាំមើល និងស្រាវជ្រាវលើករណីរំលោភសិទ្ធិមនុស្ស ករណីរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះ ត្រូវបានផ្តល់សេវាជួយជ្រោមជ្រែង តាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន និងមន្ត្រីតុលាការ។

### ជំនួយផ្នែកសេវាសុខភាព និងសេវាកម្មសង្គមកិច្ច

ក្រុមគ្រូពេទ្យផ្តល់សេវាសុខភាពដល់ជនជាប់ឃុំ និងមន្ត្រីពន្ធនាគារ ចំនួន១៤ ជនរងគ្រោះពីការរំលោភសិទ្ធិមនុស្ស និងគ្រួសារ ដែលស្ថិតនៅតំបន់តាំងទីលំនៅថ្មី។ ក្រុមការងារសេវាសង្គមធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់អ្នកទាំងនោះ ហើយផ្តល់ជំនួយ សម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

### ការប្រឹក្សាផ្នែកច្បាប់ដល់ជនជាប់ឃុំ

អ្នកប្រឹក្សាផ្នែកច្បាប់ ផ្តល់ការប្រឹក្សាដល់ជនជាប់ឃុំនៅពន្ធនាគារចំនួន១៨ ដើម្បីធ្វើឲ្យប្រាកដថា ជនជាប់ឃុំទាំងនោះមានតំណាងផ្នែកច្បាប់ នៅគ្រប់ដំណាក់កាលនៃនីតិវិធីដែលពាក់ព័ន្ធ។

### ការពិគ្រោះយោបល់ផ្នែកច្បាប់

ជនរងគ្រោះ ត្រូវបានផ្តល់ជូននូវការពិគ្រោះយោបល់ផ្នែកច្បាប់ ហើយចំពោះ ករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្តល់ជូន ដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

## កម្មវិធីលើកកម្ពស់ និងការទាក់ទាញមតិគាំទ្រ

### គាំទ្រសហជីព ក្រុមពលរដ្ឋមូលដ្ឋាន និង បណ្តាញនានា

ជួយដល់សហជីព ក្រុមពលរដ្ឋមូលដ្ឋាន និងសហគមន៍ដែលរងគ្រោះ ដោយផ្តល់នូវកិច្ចការពារសេវាកម្មផ្នែកច្បាប់ និងសេវាសុខភាព ព្រមទាំងជួយពង្រឹងសមត្ថភាពរបស់អ្នកទាំងនោះក្នុងការតស៊ូមតិ។

### ទាក់ទាញមតិគាំទ្រជាសាធារណៈ និងតាមសហគមន៍

ករណីរំលោភសិទ្ធិមនុស្ស ដែលអង្គការលីកាដូបានឃ្លាំមើល និងស្រាវជ្រាវ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យ ដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍) និងសម្រាប់ធ្វើការតស៊ូមតិផ្សេងៗទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង:**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក, ប្រធានអង្គការសិទ្ធិមនុស្ស លីកាដូ
ផ្ទះលេខ ១៦ ផ្លូវ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (+៨៥៥)២៣ ៧២៧ ១០២/២១៦ ៦០២
ទូរសារ: (+៨៥៥)២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីមែល: contact@licadho-cambodia.org
គេហទំព័រ: www.licadho-cambodia.org Facebook: www.facebook.com/licadho Twitter: www.twitter.com/licadho

# មាតិកា


សេចក្តីផ្តើម ទំព័រ១

ទិដ្ឋភាពទូទៅ៖ ប្រព័ន្ធពន្ធនាគារ និងការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ នៅកម្ពុជា ទំព័រ២

ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការដែលមិនត្រឹមត្រូវ និងអយុត្តិធម៌ ទំព័រ៣

- ស្ត្រីមានផ្ទៃពោះនិងកូនរស់នៅតាមម្តាយនៅក្នុងពន្ធនាគារ ៣
- ជនជាប់ឃុំជាអនីតិជន ៤

ការដោះលែងឲ្យនៅក្រៅឃុំ គឺជាដំណោះស្រាយមួយនៅកម្ពុជា ទំព័រ៦

សាវតាច្បាប់ ទំព័រ៨

- ការឃុំខ្លួនបណ្តោះអាសន្នអំឡុងពេលស៊ើបអង្កេត និងមុនពេលសវនាការ ១០
- ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការ ជាជម្រើសមួយ ១១

អនុសាសន៍ ទំព័រ១៣






# សេចក្តីផ្តើម

ជនជាប់ចោទពីបទល្មើសព្រហ្មទណ្ឌនៅកម្ពុជា ទទួលបាននូវសិទ្ធិសន្មត់ជាមុន ថាគ្មានទោស រហូតដល់ពេល រកឃើញថាមានទោសដោយយោងតាមច្បាប់កម្ពុជា និងអន្តរជាតិ។[១] សម្រាប់ជនជាប់ចោទភាគច្រើន នេះមានន័យថា ជាការផ្តល់ឱកាស ដល់ពួកគេជៀសវាងពីការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ តាមរយៈនីតិវិធីដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំបណ្តោះអាសន្ន។

របាយការណ៍សង្ខេបនេះ ដោយផ្អែកលើ ការងាររបស់ អង្គការលីកាដូ នៅក្នុងការឃ្លាំមើលប្រព័ន្ធពន្ធនាគារ បង្ហាញអំពីលក្ខណៈទូទៅនៃការមិនទាន់បានអនុវត្តនូវ នីតិវិធីដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំឲ្យបានពេញលេញ ដោយសារតែការអនុវត្ត ការឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នរង់ចាំសវនាការ ក្នុងរយៈពេលដ៏យូរហួសហេតុ ដែលបានបណ្តាលឲ្យមានផលវិបាក ជាច្រើន ដល់ជីវិតរបស់ជនទាំងនោះក្រុមគ្រួសារ និងសហគមន៍របស់ពួកគេ។ សម្រាប់គោលបំណងនៃរបាយការណ៍នេះ អង្គការ លីកាដូ នឹងលើកឡើងពីវិធានការនៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ដែលជាការឃុំខ្លួនជនជាប់ចោទ ដែលមិនទាន់ត្រូវបានតុលាការ ជំនុំជម្រះនៅឡើយ (ឃុំខ្លួនមុនសវនាការ)។

ផលប៉ះពាល់ នៃការឃុំខ្លួនបណ្តោះអាសន្ន រង់ចាំសវនាការ (ដោយមិនលើសពី២៧ខែ មុនពេលសវនាការ)[២] មិនអាចត្រូវបានលើកឡើងឲ្យខុសការពិតនោះទេ។ ការឃុំខ្លួនបណ្តាលឲ្យបន្សល់នូវ ស្លាកស្នាមអាក្រក់ក៏ ដូចជាបាត់បង់នូវប្រភពចំនូល និងការបែកបាក់ក្រុមគ្រួសារ នៅក្នុងសង្គមមួយ ដែលមនុស្សជាច្រើន កំពុងរស់នៅក្នុងស្ថានភាពក្រីក្រ និងពឹងផ្អែកទៅលើចំណូលគ្រួសារ។ នៅក្នុងករណីមួយចំនួន នៅពេលដែលទោសត្រូវបានសម្រេចដោយតុលាការ ជនជាប់ចោទ គឺត្រូវបានតុលាការឃុំខ្លួនរយៈពេលយូរជាងរយៈពេលទោសនៃបទល្មើស ដែលជនទាំងនោះបានប្រព្រឹត្តិទៅទៀត។ នៅក្នុងករណីផ្សេងទៀត អ្នកជាប់ពន្ធនាគារ ត្រូវបានតុលាការរកឃើញថាគ្មានទោសប៉ុន្តែអ្នកទាំងនោះត្រូវបានតុលាការឃុំខ្លួនដោយមិនត្រឹមត្រូវ ក្នុងរយៈពេល មួយដ៏យូររួចទៅហើយ។

អង្គការលីកាដូ បានធ្វើការស្រាវជ្រាវ និងធ្វើការទៅលើប្រព័ន្ធពន្ធនាគារ ចាប់តាំងពីឆ្នាំ ១៩៩៣ ដោយដំបូង ធ្វើការផ្តល់នូវសេវាពេទ្យ និងការព្យាបាល ទៅដល់អ្នកជាប់ពន្ធនាគារ ហើយបានពង្រីកសកម្មភាពទៅលើការឃ្លាំមើល និងការពារសិទ្ធិ របស់ជនជាប់ឃុំ ក៏ដូចជាសុខុមាលភាពរបស់ជនជាប់ឃុំ។ គម្រោងពន្ធនាគារ ធ្វើការងារទៅលើពន្ធនាគារចំនួន ១៨កន្លែង ក្នុងចំណោមពន្ធនាគារចំនួន ២៨ នៅទូទាំងប្រទេស។ គិតត្រឹមពេលនៃការចេញផ្សាយរបាយការណ៍នេះ អង្គការ លីកាដូ បានឃ្លាំមើលការគោរពសិទ្ធិរបស់ជនជាប់ឃុំចំនួន ២៥.៩២៦ នាក់ ដែលក្នុងនោះ ៩.៥២៧នាក់ (៣៧ភាគរយ) ត្រូវបានជាប់ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ។[៣] នៅក្នុងពន្ធនាគារមួយចំនួន ជនជាប់ឃុំ បណ្តោះអាសន្ន មានចំនួនពាក់កណ្តាល ឬច្រើនជាងនេះនៃចំនួនជនជាប់ឃុំសរុបនៅក្នុងពន្ធនាគារ។

ការកើនឡើង នៃចំនួនជនជាប់ឃុំ នៅក្នុងពន្ធនាគារកម្ពុជា ភាពចង្អៀតណែនខ្លាំង និងការជាប់ឃុំខ្លួន លើទារក ដែលតាមម្តាយយ៉ាងច្រើន គឺ (ជាផ្នែក) ដោយសារតែការមិនទាន់បានអនុវត្តឲ្យបានល្អជាប្រព័ន្ធ ទៅលើវិធានការ ឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ។ របាយការណ៍សង្ខេបនេះ ពិនិត្យទៅលើផលប៉ះពាល់អវិជ្ជមាន នៃការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្ន ដែលមានលក្ខណៈទូទៅ ដែល ត្រូវបានរកឃើញដោយបុគ្គលិកអង្គការ លីកាដូ ។របាយការណ៍នេះ ក៏វិភាគផងដែរ ទៅលើការខកខាន នៃការព្យាយាមពីមុន ក្នុងការកែទម្រង់នីតិវិធី ការដោះលែងជនជាប់ចោទឲ្យនៅក្រៅឃុំ នៅក្នុងប្រទេសកម្ពុជា និងធ្វើការផ្តល់យោបល់មួយចំនួនសម្រាប់ការអនុវត្តឲ្យបានត្រឹមត្រូវ។

[១] រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៨

[២] សម្រាប់មនុស្សវ័យជំទង់ ដែលជាប់ចោទពីបទល្មើសឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមុនពេលសវនាការ អាចត្រូវបានធ្វើឡើងរហូតដល់រយៈពេល ៦ខែ ហើយអាច នឹងពន្យាពេល ៦ខែ ពីរដងបន្ថែមទៀត (មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ដីកាដំណោះស្រាយមួយអាចនឹងត្រូវបានធ្វើឡើង ដើម្បីបន្តការឃុំខ្លួនរយៈពេល ៤ខែបន្តទៀត ដើម្បីរង់ចាំសវនាការ (មាត្រា ២៤៩)។

[៣] ស្ថិតិអង្គការលីកាដូ ពីខែឧសភា ឆ្នាំ២០១៨ ដែលផ្តល់ដោយពន្ធនាគារកម្ពុជា

# ទិដ្ឋភាពទូទៅ ៖ ប្រព័ន្ធពន្ធនាគារ និងការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនានៅកម្ពុជា

ប្រវត្តិ និងស្ថានភាពពន្ធនាគារ នៅកម្ពុជាក្នុងរយៈពេលជាច្រើនទសវត្សរ៍មកនេះ ត្រូវបានចងក្រងទុកបានយ៉ាងល្អ។[៤] កង្វះខាតថវិកាយ៉ាងខ្លាំង ភាពចង្អៀតណែនយ៉ាងធ្ងន់ធ្ងរ ការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការច្រើនហួសហេតុ ការផ្ដន្ទាទោសដោយអយុត្តិធម៌ និងមិនសមាមាត្រ ការរំលោភបំពានសិទ្ធិជនជាប់ចោទ និងអំពើដែលត្រូវបានគេអះអាងថា ជាអំពើពុករលួយយ៉ាងរីករាលដាល នៅក្នុងប្រព័ន្ធពន្ធនាគារ រួមគ្នាបង្កើតឲ្យមានស្ថានភាពពន្ធនាគារមួយ ដែលយ៉ាប់យឺន នៅក្នុងប្រទេសកម្ពុជា។ ស្ថានភាពដ៏យ៉ាប់យឺនស្រាប់នេះបានវិវឌ្ឍន៍កាន់តែធ្ងន់ធ្ងរយ៉ាងលឿន ចាប់តាំងពីដើមឆ្នាំ ២០១៧ ភាគច្រើនមកពីការចាប់ផ្ដើមយុទ្ធនាការ "សង្គ្រាមគ្រឿងញៀន" របស់រាជរដ្ឋាភិបាលកម្ពុជា នៅពេលនោះចំនួននៃជនជាប់ឃុំ បានកើនឡើងយ៉ាងខ្លាំង។

ឧទាហរណ៍ គិតត្រឹម ពេលដែលចេញផ្សាយរបាយការណ៍នេះ មណ្ឌលអប់រំកែប្រែទី១ (ម១) ដែលជាពន្ធនាគារធំមួយ ផ្ទុកអ្នកទោសបុរស នៅរាជធានីភ្នំពេញ មានផ្ទុក អ្នកជាប់ឃុំចំនួន ៦.៧១១ នាក់[៥] ទោះជាពន្ធនាគារនេះ ត្រូវបានគេកសាងឡើងដើម្បី ផ្ទុកអ្នកជាប់ពន្ធនាគារត្រឹម ២.០៥០ នាក់ ក៏ដោយ។ នេះមានន័យថា ពន្ធនាគារនេះកំពុងផ្ទុកមនុស្ស បីដង លើសពីចំនួន ដែលអាចផ្ទុកបានតាមបទដ្ឋាន។[៦] ស្ទើរតែ ៥០% នៃអ្នកជាប់ពន្ធនាគារទាំងនោះ គឺជាអ្នកជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ[៧] ដែលភាគច្រើននៃអ្នកទាំងនោះមានលក្ខណៈសម្បត្តិ ទទួលបានការដោះលែងនៅក្រៅឃុំ ប៉ុន្តែមិនដែលទទួលបានឱកាស ដើម្បីទទួលបាននោះទេ ដោយសារកង្វះខាតជំនួយ ផ្នែកច្បាប់ ឬព្រោះតែពួកគេមិនបានដឹងអំពីសិទ្ធិ របស់ពួកគេក្នុងការដាក់ពាក្យស្នើសុំ។ ការប្រើប្រាស់ នីតិវិធីដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន នឹងជាដំណោះស្រាយមួយ ទៅលើបញ្ហានៃភាពចង្អៀតណែន ក្នុងពន្ធនាគារ។



## អ្វីទៅជាការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន?

ការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន គឺជាមធ្យោបាយផ្លូវច្បាប់មួយ ដែលមានគោលបំណងលើកទឹកចិត្ត ជនជាប់ចោទ ឲ្យចូលមកតុលាការ ជាងវិធីសាស្ត្របង្ខំ ដាក់ពន្ធនាគារបណ្ដោះអាសន្ន។ ជនជាប់ចោទ យល់ព្រមនឹងចូលខ្លួន ក្នុងតុលាការ និងគោរពតាមលក្ខខណ្ឌ ជាក់លាក់មួយចំនួន មុនពេលមានសវនាការលើសំណុំរឿង របស់ជននោះ ជាថ្នូរនឹង សេរីភាពរបស់ខ្លួន។ នៅក្នុងប្រទេស មួយចំនួន ជនជាប់ចោទ តំកល់ប្រាក់នៅតុលាការ ឬ ប័ណ្ណធានាជាការធានាថា ជននោះនឹងត្រលប់ចូលខ្លួន មកសវនាការ របស់ខ្លួន ដើម្បីទទួលការជំនុំជម្រះ។ លក្ខខណ្ឌតម្រូវនៃច្បាប់ សម្រាប់ការដោះលែង ឲ្យនៅក្រៅឃុំនេះ អាចត្រូវ បានគេមើលឃើញថា ជាមធ្យោបាយសម្របសម្រួលមួយរវាងគោលការណ៍ជាមូលដ្ឋាន នៃការសន្មត់ជាមុនថាគ្មានទោស ដែលមានចែង នៅក្នុងបទដ្ឋាន សិទ្ធិមនុស្សអន្តរជាតិ និង ការអនុវត្ត ជាក់ស្ដែង ដើម្បីធានាថា ជនជាប់ចោទ ចូលខ្លួន នៅមុខតុលាការ។

---

[៤] សូមមើល របាយការណ៍ អង្គការ លីកាដូ៖ "សិទ្ធិនៅលើការទិញដូរ៖ ជីវិតនៅក្នុងពន្ធនាគារកម្ពុជា" http://www.licadho-cambodia.org/collection/25/life_inside_cambodia_prison?khmer ; "ទំហំដែលផ្ទុកអ្នកទោសបាន ឆ្នាំ២០១២៖ ការវិវឌ្ឍន៍នៃរបាយការណ៍ស្ដីពីភាពចង្អៀតណែនរបស់អ្នកទោសនៅកម្ពុជា" http://www.licadho-cambodia.org/reports.php?perm=168&khmer

[៥] ស្ថិតិអង្គការលីកាដូ ពីខែឧសភា ឆ្នាំ២០១៨ ដែលផ្ដល់ដោយពន្ធនាគារកម្ពុជា

[៦] នៅខណៈ ដែលមិនមានច្បាប់កម្ពុជាជាក់លាក់ណាមួយ កំនត់ពីបទដ្ឋានអប្បបរមានៃស្ថានភាពនៅក្នុងបន្ទប់ពន្ធនាគារ វិធាន ១២ និង១៣ នៃវិធានបទដ្ឋានអប្បបរមាសម្រាប់ជនជាប់ឃុំ (ជាទូទៅ ត្រូវបានគេហៅថា វិធានអន្តរជាតិ ណេលសុន មេនដេឡា) បានលើកឡើងអំពីលក្ខខណ្ឌនៃការរស់នៅរបស់ជនជាប់ឃុំក្នុងពន្ធនាគារ។ វិធាន ១៣ បានលើកឡើងថា" គ្រប់ការស្នាក់អាស្រ័យដែលត្រូវបានផ្ដល់ដល់ជនជាប់ឃុំ ហើយជាពិសេសគ្រប់កន្លែងសំរាន្តទាំងអស់ ត្រូវបំពេញនូវលក្ខខណ្ឌនៃសុខភាព ដោយផ្អែកលើលក្ខខណ្ឌអាកាសធាតុ និងជាពិសេសរង្វាស់ខ្យល់ ទីធ្លារអប្បបរមានៅក្នុងបន្ទប់ ពន្លឺ កំដៅ និងប្រព័ន្ធខ្យល់ចេញចូល"។

[៧] នៅពេលចេញរបាយការណ៍នេះ អ្នកជាប់ឃុំចំនួន ៣.៣១៩នាក់ ស្មើនឹង ៤៩% នៅក្នុងពន្ធនាគារ ម១ គឺជាអ្នកជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ ឬរង់ចាំសាលដីកាចុងក្រោយ។ អ្នកជាប់ពន្ធនាគារចំនួន ៩.៥២៧ នាក់ គឺជាជនជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ ក្នុងចំណោមអ្នកជាប់ពន្ធនាគារសរុបចំនួន ២៥.៩២៦ នៅក្នុងពន្ធនាគារចំនួន ១៨ កន្លែង ដែលត្រូវបាន ឃ្លាំមើលដោយអង្គការ លីកាដូ។

# ការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ ដែលមិនត្រឹមត្រូវ និងអយុត្តិធម៌

## ស្ត្រីមានផ្ទៃពោះ និងកូនរស់នៅតាមម្ដាយ នៅក្នុងពន្ធនាគារ

ផលប៉ះពាល់មួយ ក្នុងចំណោមផលប៉ះពាល់យ៉ាងខ្លាំងផ្សេងទៀត នៃការប្រើប្រាស់ការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ ច្រើនហួសហេតុ គឺជាការកើនឡើង នៃចំនួនស្ត្រីមានផ្ទៃពោះ និងម្ដាយដែលមានកូនតូចនៅទន់ខ្សោយរស់នៅជាមួយ ក្នុងពន្ធនាគារ។ តាមច្បាប់កម្ពុជា កុមារដែលនៅក្រោមអាយុបីឆ្នាំ អាចរស់នៅក្នុងពន្ធនាគារជាមួយម្ដាយដើម្បីទទួលបានការបីបាច់ថែរក្សាពីម្ដាយ។[៨] ដោយសារយុទ្ធនាការ "សង្គ្រាមគ្រឿងញៀន" របស់រាជរដ្ឋាភិបាល និងការកំពុងកើនឡើងនៃចំនួនអ្នកជាប់ក្នុងពន្ធនាគារ ចំនួននៃកុមាររស់នៅជាមួយម្ដាយនៅក្នុងពន្ធនាគារ ដែលបានឃ្លាំមើល ដោយអង្គការ លីកាដូ បានកើនឡើង យ៉ាងខ្លាំង ពីចំនួន៣០នាក់ នៅចុងឆ្នាំ២០១៥ កើនដល់ចំនួន ១៣៨នាក់ នាបច្ចុប្បន្ននេះ។[៩]

កុមារអាយុក្រោមបីឆ្នាំ គឺស្ថិតក្នុងចំណោមប្រភេទ ជនជាប់ឃុំដែលងាយរងគ្រោះបំផុត។ ការឃុំខ្លួនរបស់កុមារទាំងនោះ កើតចេញដោយផ្ទាល់ពីការឃុំខ្លួនដោយមិនត្រឹមត្រូវ និងការបដិសេធការសុំនៅក្រៅឃុំបណ្ដោះអាសន្នរបស់ម្ដាយ។ អំឡុងឆ្នាំ ២០១៧ កុមាររស់នៅក្នុងពន្ធនាគារ មានចំនួនខ្ពស់បំផុតមិនធ្លាប់មាន គឺ ១៧៩ នាក់ (ភាគច្រើនមានអាយុក្រោម២ឆ្នាំ) ហើយនិងស្ត្រីមានផ្ទៃពោះចំនួន៧៤នាក់ បានជាប់ក្នុងពន្ធនាគារ។ នៅក្នុងខែកក្កដា ឆ្នាំ២០១៨ មានកុមារចំនួន ១៣៨ នាក់ កំពុងរស់នៅជាមួយម្ដាយចំនួន ១៣៥ នាក់ ហើយនិងមានស្ត្រីមានផ្ទៃពោះចំនួន ៣០នាក់។ ស្ទើរជិតពាក់កណ្ដាល នៃអនាគតម្ដាយ (៨០នាក់) កំពុងត្រូវបានតុលាការ ឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ។

អង្គការ លីកាដូ បានធ្វើការទៅលើករណីជាច្រើន ដែលស្ត្រីមានកូនតូច និងទារករស់នៅជាមួយ មិនមានជម្រើសអ្វី ក្រៅពីការយកកូនតូច និងទារកទាំងនោះ មករស់នៅក្នុងពន្ធនាគារជាមួយនោះទេ។ នៅក្នុងករណីមួយចំនួន នៅពេលកូនរបស់ពួកគេ ឈានដល់អាយុបីឆ្នាំហើយមិនអាចឲ្យរស់នៅជាមួយក្នុងពន្ធនាគារ បានតទៅទៀត កូនទាំងនោះ ត្រូវបានគេបង្ខំឲ្យរស់នៅក្នុងមណ្ឌលថែរក្សា។

**ដោយសារយុទ្ធនាការ "សង្គ្រាមគ្រឿងញៀន" របស់រាជរដ្ឋាភិបាល ចំនួននៃកុមាររស់នៅជាមួយម្ដាយនៅក្នុងពន្ធនាគារ បានកើនឡើងយ៉ាងខ្លាំង ពីចំនួន ៣០នាក់ នៅចុងឆ្នាំ ២០១៥ កើនដល់ចំនួន ១៣៨នាក់ គិតត្រឹមខែកក្កដា ឆ្នាំ២០១៨។**

ផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំង នៃការរីកធំធាត់ នៅក្នុងពន្ធនាគារកម្ពុជា ត្រូវបានចងក្រងទុកយ៉ាងល្អ។[១០] កុមារតូចៗទាំងនេះ នឹងទទួលយកនូវផលវិបាកអវិជ្ជមាន ជាប់មួយជីវិត របស់ពួកគេនៅពេលកុមារទាំងនោះ រស់នៅក្នុងពន្ធនាគារ។ ការប្រើប្រាស់នីតិវិធីដោះលែងឲ្យនៅក្រៅឃុំ ឲ្យបានត្រឹមត្រូវ នឹងអាចជួយធានាថាម្ដាយជាច្រើន មិនត្រូវបានគេបង្ខំឲ្យចិញ្ចឹមបីបាច់ ទារក នៅក្នុងបន្ទប់ពន្ធនាគារ ដែលមានភាពចង្អៀតណែន ដោយមិនចាំបាច់នោះទេ ហើយនឹងការពារ ពីផលវិបាកជាច្រើន ដែលនឹងអាចនៅជាប់ជាមួយកុមារតូចៗ ដែលរីកធំធាត់ក្នុងពន្ធនាគារ ដែលមានស្ថានភាពមិនស្អាត និង មិនល្អ ជាច្រើន។

កុមារនឹងទទួលបាននូវបទពិសោធន៍ ពីស្ថានភាព មិនល្អនៅក្នុងពន្ធនាគារ នៅពេលរស់នៅជាមួយម្ដាយ នៅចំនុចណាមួយ នៃការវិវឌ្ឍន៍ ផ្នែករាងកាយ និងផ្លូវចិត្តរបស់ពួកគេ នៅខណៈពេលដែលមានការខ្វះខាតម្ហូបអាហារ និងធនធាន ហើយនិងកង្វះខាត ទំនាក់ទំនងជាមួយគ្រួសារ និងសហគមន៍របស់ពួកគេ។ ស្ត្រីមានផ្ទៃពោះជាច្រើន មិនទទួលបានការថែទាំសុខភាពមុន ឬក្រោយពេលសម្រាលកូននោះទេ ហើយនៅក្នុងករណីមួយចំនួន ត្រូវបានបង្ខំឲ្យ ត្រឡប់មកពន្ធនាគារវិញ មួយថ្ងៃបន្ទាប់ពីសម្រាលកូនរួច។

[៨] មាត្រា ៤១ នៃច្បាប់ស្ដីពីពន្ធនាគារ បានចែងថា "កុមារតាមម្ដាយ ត្រូវបានអនុញ្ញាតឲ្យស្នាក់នៅជាមួយម្ដាយត្រឹមអាយុ បីឆ្នាំ និងត្រូវបានផ្ដល់ម្ហូបអាហារ សម្លៀកបំពាក់ និងសេវាថែទាំសុខភាព"។

[៩] គិតត្រឹមខែកក្កដា ឆ្នាំ២០១៨

[១០] សូមមើលរបាយការណ៍អង្គការ លីកាដូ ដែលមានចំណងជើងថា៖ "កុមារភាពនៅក្នុងពន្ធនាគារ ការចម្រើនវ័យក្នុងពន្ធនាគារកម្ពុជា៖ រឿងរ៉ាវរបស់ដារ៉ា" http://www.licadho-cambodia.org/reports/files/203kLICADHOReportChildhoodBehindBars-Khmer.pdf ; "កុមារ ភាពនៅក្នុងពន្ធនាគារ៖ ការចម្រើនវ័យនៅក្នុងពន្ធនាគារកម្ពុជា៖ រឿងរ៉ាវ របស់សុខ គុន" http://www.licadho-cambodia.org/reports/files/182kLICADHOReportChildrenBehindBars2013-Khmer.pdft; អ្នកជាប់ពន្ធនាគារដែលមិនមានកំហុស៖ របាយការណ៍អង្គការ លីកាដូ ស្ដីពីសិទ្ធិរបស់កុមារចម្រើនវ័យនៅក្នុងពន្ធនាគារ https://www.licadho-cambodia.org/reports/files/34Children%20in%20Prisons%20with%20Cover%20page.pdf



## ទារកដែលរស់នៅក្នុងពន្ធនាគារ

នាងខ្ញុំឈ្មោះ សុខ ឡៃ។*នាងខ្ញុំជាប់នៅក្នុងពន្ធនាគារជាមួយកូនរបស់ខ្ញុំ។ មុនពេលត្រូវបាននគរបាលចាប់ខ្លួន នាង ខ្ញុំរស់នៅជាមួយមិត្តភ័ក្រ្តនាងខ្ញុំម្នាក់ និងកំពុងមានផ្ទៃពោះរយៈពេលពីរបីខែ។ នាងខ្ញុំ និងមិត្តភ័ក្រ្តនាងខ្ញុំ ត្រូវបាននគរបាលឃាត់ខ្លួន និងចាប់ខ្លួន ដាក់ពន្ធនាគារពីបទ ល្មើសពាក់ព័ន្ធនឹងគ្រឿងញៀន។ នាងខ្ញុំបានប្រាប់នគរបាលទាំងនោះថា នាងខ្ញុំមិនដែលធ្លាប់ប្រើប្រាស់ ឬក៏លក់ គ្រឿងញៀននោះទេ ប៉ុន្តែនគរ បាលទាំងនោះ មិនបានស្តាប់នាង ខ្ញុំនោះទេ។ នាងខ្ញុំ បានប្រាប់ពួកគេ ថា នាងខ្ញុំមានផ្ទៃពោះរយៈពេល ប្រាំខែហើយ ប៉ុន្តែនគរបាលទាំង នោះមិនបាន ខ្វល់នោះឡើយ។

នគរបាល បានបញ្ជូននាងខ្ញុំ ទៅដាក់នៅក្នុងបន្ទប់ឃុំឃាំងមួយដែលចង្អៀតខ្លាំង ហើយអ្នកជាប់ពន្ធនាគារ ផ្សេងទៀត បានឲ្យខ្ញុំសម្រាន្តនៅលើឥដ្ឋ។ ទោះជានាងខ្ញុំមានផ្ទៃពោះក៏ដោយក៏នាងខ្ញុំមិនត្រូវបានគេផ្តល់អាហារបន្ថែម ឬ ការថែទាំផ្នែកវេជ្ជសាស្រ្តអ្វីនោះទេ។ នៅពេលដែលអ្នកជាប់នៅក្នុងពន្ធនាគារ ប្រសិនបើអ្នក សំណាង ក្រុមគ្រួសាររបស់អ្នក អាចមកសួរសុខទុក្ខអ្នក និងយកអាហារ សាប៊ូ និង អ្វីផ្សេងៗទៀត ដែលអ្នក ត្រូវការ មកឲ្យអ្នក។ ក្រុម គ្រួសាររបស់នាងខ្ញុំរស់នៅក្នុង ខេត្តមួយ ហើយនៅឆ្ងាយ ដែលធ្វើឲ្យអ្នកទាំងនោះពិបាកមកសួរសុខ ទុក្ខនាងខ្ញុំ។ នាងខ្ញុំតែងតែឃ្លាន។

នៅពេលដែលនាងខ្ញុំ ឈឺពោះសម្រាលកូន ឆ្មាំពន្ធនាគារ មួយចំនួន បាននាំនាងខ្ញុំទៅមន្ទីរពេទ្យ។ មានឆ្មាំពន្ធនាគារ ពីរនាក់ដែលនៅក្រៅបន្ទប់របស់នាងខ្ញុំ។ នាងខ្ញុំត្រូវបានគេអនុញ្ញាតឲ្យ ស្នាក់នៅក្នុងមន្ទីរពេទ្យត្រឹមតែរយៈពេលមួយថ្ងៃប៉ុណ្ណោះ។ នៅថ្ងៃបន្ទាប់ពីកូនរបស់ នាង ខ្ញុំបានកើត ឆ្មាំព ន្ធ នា គារ បានបញ្ជូននាងខ្ញុំ ត្រលប់ទៅពន្ធនាគារវិញ។ កូនរបស់នាងខ្ញុំ បានយំយ៉ាងខ្លាំង ហើយខ្ញុំ គិតថានាងឃ្លាន ខ្លាំង ព្រោះខ្ញុំមិនមានទឹកដោះគ្រប់គ្រាន់សម្រាប់នាងបៅ។ នាងខ្ញុំមានការព្រួយបារម្ភ ថា កូនរបស់នាងខ្ញុំនឹងរំខាន ដល់អ្នកជាប់ពន្ធនាគារផ្សេងទៀត នៅក្នុងបន្ទប់តែមួយ។ ឆ្មាំ ពន្ធនាគារ មិនបានឲ្យអាហារបន្ថែម ដើម្បីជួយឲ្យខ្ញុំមានទឹកដោះ ច្រើននោះទេ ដូចនេះមួយរយៈក្រោយមក នាងខ្ញុំត្រូវប្រើម្សៅទឹកដោះគោជំនួស។ មានអង្គការមួយ បានឲ្យ នាងខ្ញុំនូវម្សៅទឹកដោះគោ និងដបទឹកដោះគោមួយចំនួន ប៉ុន្តែមានការលំបាក ក្នុងការរកទឹកស្អាតមកលាយជាមួយម្សៅទឹកដោះគោ ឬលាងសម្អាតដប។ កូននាងខ្ញុំតែងតែ ឃ្លានបៅ។ នាងយំមិនឈប់សោះ។

នាងខ្ញុំមិនមានកន្ទប ឬសំលៀកបំពាក់គ្រប់គ្រាន់ សម្រាប់កូនរបស់នាងខ្ញុំនោះទេ។ នាងខ្ញុំ មិនដែលទទួល បានសាប៊ូអ្វី ដើម្បី លាងសំអាតកូនរបស់នាងខ្ញុំនោះទេ។ ដូចនេះ ខ្ញុំតែងតែបារម្ភថា កូននាងខ្ញុំអា ច នឹ ង ឈឺ ។ នាងខ្ញុំ បានសួរឆ្មាំពន្ធនាគារ ប្រសិនបើអ្នកទាំងនោះអាចជួយនាងខ្ញុំ ចុះឈ្មោះកូនខ្ញុំក្នុងបញ្ជីកំណើត ប៉ុន្តែ ពួកគេបាននិយាយថា នេះមិនមែនការងាររបស់ពួកគេដែលត្រូវ ជួយនាងខ្ញុំនោះទេ។

ពីរបីខែ ក្រោយពីកូនរបស់នាងខ្ញុំបានកើត នាងខ្ញុំបានចូលរួមក្នុងសវនាការលើរឿងក្តីរបស់នាងខ្ញុំ ហើយនាងខ្ញុំត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារថែមមួយឆ្នាំទៀត។

*សំគាល់៖ ឈ្មោះ និងលក្ខណៈអត្តសញ្ញាណផ្សេងទៀតខាងលើ ត្រូវបានប្តូរ ដើម្បីការពារអត្តសញ្ញាណពិតរបស់អតិថិជន

## ជនជាប់ឃុំជាអនីតិជន

ក្រុមដែលងាយរងគ្រោះដទៃទៀត ក៏ទទួលរងគ្រោះដោយការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ច្រើនហួសហេតុនេះផងដែរ។ ការអនុវត្តច្បាប់នៅ ទន់ខ្សោយ មានន័យថា អ្នកទាំងនោះមិនអាចទទួលបានអត្ថប្រយោជន៍ ពីការការពារនៃច្បាប់នោះទេ។ មាត្រា ២១២ ២១៣និង ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានកម្រិតរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ លើអនីតិជនអាយុចាប់ពី ១៦ដល់ ១៨ឆ្នាំ ដែលត្រូវបាន តុលាការចោទប្រកាន់ពីបទល្មើសឧក្រិដ្ឋ និងហាមឃាត់ ការឃុំខ្លួនជនណា ដែលមានអាយុតិចជាង ១៤ឆ្នាំ។ ការកម្រិត នេះ ជាក់ស្តែង មិនសូវដែលត្រូវបាន គេអនុវត្តនោះទេ ហើយអង្គការ លីកាដូ បានសម្ភាសន៍ជនជាប់ឃុំអនីតិជនមួយចំនួន ដែលការឃុំ ខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ របស់អ្នកទាំងនោះលើសរយៈពេលកំណត់នៃច្បាប់។ នៅពេលដែលពួកគេ ជាប់នៅក្នុងពន្ធនាគារ ការសិក្សារបស់អ្នកទាំងនោះ នឹងត្រូវផ្អាក ហើយទំនាក់ទំនងជាមួយក្រុមគ្រួសារ និងសហគមន៍ របស់ពួកគេក៏នឹងត្រូវឃ្លាតឆ្ងាយ។ ការស្រាវជ្រាវយ៉ាងទូលំទូលាយ នៅក្នុងប្រទេសដទៃបានបង្ហាញថា ការដាក់ឲ្យជនជាប់ឃុំអនីតិជន ជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ គឺឲ្យអ្នកទាំងនោះរស់នៅជាមួយ និងរៀនតាមអាកប្បកិរិយា មិនល្អរបស់ជនជាប់ឃុំជានីតិជន ហើយអាចធ្វើឲ្យមនុស្សជំនាន់ក្រោយ ឈានទៅដល់ការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌធ្ងន់ធ្ងរនាពេលអនាគត។[១១]

មនុស្សជាច្រើន រួមមានអនីតិជន និងស្ត្រីមានផ្ទៃពោះ ត្រូវបានតុលាការឃុំខ្លួនដោយមិនចាំបាច់។ ការណ៍នេះអាចត្រូវបានឃើញតាមរយៈស្ថិតិ ដែលទទួលបានពីពន្ធនាគារចំនួន ១៨ ដែលអង្គការ លីកាដូ បានធ្វើការឃ្លាំមើល។ ដោយការ អនុវត្តការឃុំខ្លួនបណ្តោះអាសន្ន គ្រប់ពេលចៅក្រមបាន ត្រឡប់គោលការណ៍សន្មត់ជាមុនថាគ្មានទោស៖ ឥឡូវជនជាប់ចោទ ត្រូវតែ ជាប់ក្នុងការឃុំឃាំងរហូតដល់ពេលដែលចៅក្រម អាចកំណត់ពេល វេលាសវនាការជំនុំជម្រះហើយរកឃើញថាជននោះគ្មានទោសទើបដោះលែង។ អង្គការ លីកាដូបានសម្ភាសជនជាប់ឃុំជាច្រើន ដែលត្រូវបានគេដាក់ ឲ្យជាប់ ឃុំបណ្តោះអាសន្ន អស់រយៈពេលរាប់ខែ ដោយមិនមានកាលបរិច្ឆេទសវនាការ ឬមិនមានជំនួយផ្នែក ច្បាប់ ហើយអ្នក ទាំងនោះ មិនដឹងអំពីព័ត៌មានលំអិត នៃបទចោទប្រកាន់ មកលើអ្នកទាំងនោះ នោះទេ។ នៅក្នុងករណីមួយ អង្គការ លីកាដូ បានសម្ភាសជនជាប់ពន្ធនាគារម្នាក់ ដែលត្រូវបានតុលាការដាក់ឲ្យ ជាប់ឃុំឃាំងបណ្តោះអាសន្នរង់ចាំសវនាការអស់រយៈពេលពីរឆ្នាំ ដោយមិនដែលបានជួបមេធាវី ឬមិនដែលទទួលបានការឲ្យដំណឹង ឲ្យបានត្រឹមត្រូវពីបទចោទប្រកាន់មកលើរូបខ្លួននោះទេ។



[១១] ជាឧទាហរណ៍ សូមមើលអត្ថបទមានចំណងជើងថា៖ “The Dangers of Detention: The Impact of Incarcerating Youth in Detention and Other Secure Facilities”, A Justice Policy Institute, របស់លោក Barry Holman and Jason Ziedenberg : http://www.justicepolicy.org/images/upload/06-11_rep_dangersofdetention_jj.pdf

# ការដោះលែងឲ្យនៅក្រៅឃុំ គឺជាដំណោះស្រាយមួយ

នៅខណៈ ដែលហេតុផលនយោបាយមួយចំនួន ដែលមិនត្រូវបាន បញ្ចេញឲ្យដឹង អាចដើរតួនាទី នៅក្នុងសេចក្តីសម្រេចចិត្តរបស់តុលាការ ក្នុងការបដិសេធការដោះលែងឲ្យនៅក្រៅឃុំ ចំពោះជនជាប់ឃុំមួយចំនួន ដែលអាជ្ញាធររដ្ឋគិតថាអាចបង្កហានិភ័យដល់រដ្ឋាភិបាល និង បុគ្គលមានឥទ្ធិពលមួយចំនួន ហេតុផលទាំងនោះជាក់ស្តែង មិនមាននៅក្នុងសំណុំរឿងធម្មតាភាគច្រើន ដែលត្រូវបានតាមដានដោយអង្គការ លីកាដូ នោះទេ។ ជាការអនុវត្ត ការដោះលែងឲ្យនៅក្រៅឃុំ មិនត្រូវបានតុលាការអនុញ្ញាត សូម្បីតែចំពោះជនដែលត្រូវបានចោទប្រកាន់ពីបទល្មើស ដែលកើតឡើងញឹកញាប់ និងបទល្មើស ដែលគ្មានអំពើហិង្សានានា ក៏ដោយ។

"ការមិនអាចអនុវត្តនូវមាត្រាមួយចំនួនពាក់ព័ន្ធនឹងការដោះលែងឲ្យនៅក្រៅឃុំឲ្យមានប្រសិទ្ធិភាព មានន័យថារាជរដ្ឋាភិបាលមិនគោរពនូវគោលការណ៍គតិយុត្តិ ដែលសន្មត់ជាមុនថាគ្មានទោស ហើយរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងការមានសេរីភាព រហូតទាល់តែត្រូវបានរកឃើញថាមានទោស"។

ការមិនអាចអនុវត្ត នូវមាត្រាពាក់ព័ន្ធ នឹងការដោះលែងឲ្យនៅក្រៅឃុំឲ្យមានប្រសិទ្ធិភាព មានន័យថារាជរដ្ឋាភិបាល មិនគោរពនូវគោលការណ៍គតិយុត្តិ ដែលសន្មត់ជាមុនថាគ្មានទោស ហើយរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងការមានសេរីភាព រហូតទាល់តែ ត្រូវបានរកឃើញថាមានទោស។ បន្ថែមពីលើការជួយសម្រាល នូវការចង្អៀតណែនយ៉ាងខ្លាំង និងការដាក់ជនដែលងាយរងគ្រោះឲ្យជាប់ឃុំឃាំង ការអនុវត្តឲ្យបានត្រឹមត្រូវ នូវនីតិវិធីនៃការដោះលែងឲ្យ នៅក្រៅឃុំ អាចជួយកាត់បន្ថយការរំលោភបំពាន ដែលត្រូវបានគេអះអាងថា កំពុងរីករាលដាលទាំងនេះ។ បច្ចុប្បន្ននេះ មនុស្សភាគច្រើន ដែលជាប់ចោទ ពីបទព្រហ្មទណ្ឌ គឺត្រូវបានតុលាការដាក់ឲ្យនៅជាប់ឃុំឃាំងភ្លាមៗ ដែលផ្ទុយពីច្បាប់របស់កម្ពុជា ដែលមានស្រាប់ ដែលបានអំពាវនាវ ឲ្យមានការដោះលែងឲ្យនៅក្រៅឃុំ នៅក្នុងគ្រប់ករណី លើកលែងតែករណីមួយចំនួន ដែលមានភាពចាំបាច់។

## ការគ្មានជំនួយផ្លូវច្បាប់ និងការមិនដឹងអំពីសិទ្ធិសុំនៅក្រៅឃុំបណ្តោះអាសន្ន

ខ្ញុំឈ្មោះ ធី*។ខ្ញុំធ្លាប់ធ្វើការនៅខេត្តព្រៃវែង ជាកម្មករ។ ថ្ងៃមួយខ្ញុំបានទៅលេងក្រុមគ្រួសាររបស់ខ្ញុំនៅឯស្រុកកំណើត។ នគរបាលបានមកដល់ផ្ទះរបស់ខ្ញុំ ហើយស្វែងរកអ្វីមួយ។ នគរបាលទាំងនោះ បានឆែកឆេរផ្ទះទាំងមូល ហើយរកឃើញគ្រឿងញៀនចំនួន ១ក្រាម នៅក្រោមពូកគេងមួយ។ គ្រឿងញៀន និងពូកគេងនោះ មិនមែនជារបស់ខ្ញុំនោះទេ។ ខ្ញុំមិនបានទាំងស្គាល់ថ្នាំដែលពួកគេ រកឃើញនោះផង ។ នគរបាលទាំងនោះ មិនបានស្តាប់ពួកយើងនោះទេ ហើយបែរជាចាប់ស្ទើរតែទាំងអស់អ្នកដែលរស់នៅក្នុងផ្ទះនេះ (ទាំងអស់មានគ្នា ១០នាក់ រួមទាំងសមាជិកគ្រួសាររបស់ខ្ញុំ និងមិត្តភ័ក្ត្ររបស់ខ្ញុំ ហើយនិងខ្ញុំ)។

នគរបាល ទាំងនោះ បានប្រាប់ខ្ញុំថា ខ្ញុំកំពុងត្រូវបានចាប់ខ្លួន ពីបទជួញដូរគ្រឿងញៀន។ ខ្ញុំមិនត្រូវបានគេជួយរកមេធាវីឲ្យនោះទេ។ ខ្ញុំមិនដឹងថាអ្វី ជាការសុំនៅក្រៅឃុំនោះទេ។ មិនមានអ្នកណាម្នាក់ មកប្រាប់ខ្ញុំអំពីរឿងនេះទេ។ នគរបាល បានបញ្ជូនពួកយើងទាំងអស់គ្នា ទៅក្នុងពន្ធនាគារ ។ ខ្ញុំរស់នៅក្នុងបន្ទប់ពន្ធនាគារមួយ ដែលមានគ្នា ១៣៤នាក់។ ខ្ញុំ មិនមានប្រាក់កាសនោះទេ ដូចនេះខ្ញុំមិនអាចទិញម្ហូបអាហារបន្ថែម ឬចំណាយថ្លៃចេញក្រៅបន្ទប់ បន្ថែមនោះទេ។ ខ្ញុំ មិនមាន អាហារបរិភោគគ្រប់គ្រាន់នោះទេ ហើយខ្ញុំតែងតែឃ្លាន។ ខ្ញុំ ត្រូវបានគេអនុញ្ញាតឲ្យចេញក្រៅបន្ទប់ តែពីដងប៉ុណ្ណោះ ក្នុងមួយថ្ងៃ (ម្តង ១៥នាទី)។

ពួកយើង ទាំងដប់នាក់ ត្រូវបានតុលាការផ្តន្ទាទោស ពីបទជួញដូរគ្រឿងញៀន និង ដាក់ឲ្យជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ។ យើងមិនជឿថារឿងនេះកើតឡើង បែបនេះនោះទេ។ គ្នាយើងមួយចំនួន បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងសាលក្រមនេះ ប៉ុន្តែមួយចំនួនទៀត មានការភ័យខ្លាចនឹងការប្តឹងឧទ្ធរណ៍នេះ។

*សំគាល់៖ ឈ្មោះ និងលក្ខណៈអត្តសញ្ញាណផ្សេងទៀតខាងលើ ត្រូវបានប្តូរ ដើម្បីការពារអត្តសញ្ញាណពិតរបស់អតិថិជន

ប្រសិនបើការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ ត្រូវបានកម្រិតត្រឹមតែ លើករណីមួយចំនួន ដែលចាំបាច់បំផុត នោះស្ថាប័នតុលាការ នឹងត្រូវផ្តល់អាទិភាព ក្នុងការឃុំខ្លួនលើករណីជាច្រើន ដោយយោងតាមភាពធ្ងន់ធ្ងររបស់ករណីទាំងនោះ ដែលនោះ អាចជួយសម្រាលទំហំការងារ ដែលកំពុងច្រើនស្រាប់នៅក្នុងស្ថាប័នតុលាការ និង ប្រព័ន្ធពន្ធនាគារ ហើយជនជាប់ចោទ នៅតែអាចចូលទៅក្នុងសង្គម រហូតដល់ពេលពួកគេត្រូវបានគេរកឃើញថា មានទោស។

ក៏ប៉ុន្តែ ប្រសិនបើនីតិវិធីនៃការដោះលែងឲ្យនៅក្រៅឃុំ ត្រូវបានគេអនុវត្តឲ្យបានត្រឹម ត្រូវ នោះវានឹងមានសារ សំខាន់ ដើម្បីធានាថា នីតិវិធីទាំងនោះ មិនត្រូវបានគេ ប្រើប្រាស់ជាមធ្យោបាយមួយ ដើម្បីដាក់ពិន័យដល់ជនក្រីក្រ និងដាក់អ្នក ដែលមិនមានលទ្ធភាពបង់ប្រាក់កាសនៅក្នុងពន្ធនាគារនោះឡើយ។[១២] នៅក្នុងករណី អ្នកទោសមនសិការ ការលើកលែងកាចោទប្រកាន់ ដែលមានលក្ខណៈមិនប្រក្រតី និង មិនមានមូលដ្ឋានច្បាប់ត្រូវតែជាការងារអាទិភាព មុនពេលមានការអនុវត្តនីតិវិធី នៃការដោះលែង ឲ្យនៅក្រៅឃុំដើម្បីជៀសវាងការគម្រាម កំហែងថានឹងចាប់ខ្លួនមកវិញ។[១៣]

កាលពីខែមករា ឆ្នាំ២០១៤ ការិយាល័យនៃឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា (OHCHR) សហការជាមួយស្ថាប័នតុលាការ កម្ពុជា បានបង្កើតនូវទម្រង់ថ្មីមួយចំនួនដែលមានគោលបំណង ធ្វើជាមធ្យោបាយមួយ សម្រាប់ចៅក្រមប្រើប្រាស់ក្នុងការកំណត់ថា តើពេលណាដែលការឃុំខ្លួនជនជាប់ ចោទបណ្តោះអាសន្ន ជាការចាំបាច់ស្របច្បាប់។[១៤] គោលបំណង គឺដើម្បីលើកកំពស់ការយល់ដឹងរបស់ចៅក្រមកម្ពុជា អំពីលក្ខខណ្ឌ សម្រាប់ការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ និងដើម្បីពន្លឿននូវនីតិវិធី ដើម្បីជួយពួកគេ ក្នុងការ អនុវត្តលក្ខខណ្ឌ ដូចដែលមានចែងនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធី ព្រហ្មទណ្ឌឲ្យបានត្រឹមត្រូវ។ នៅពេលដែល ការិយាល័យ នៃឧត្តម ស្នងការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស នៅកម្ពុជារាយការណ៍ថា ខ្លួនបានកត់សំគាល់ឃើញមានការកើនឡើងនូវ ចំនួនចៅក្រម ដែលបានប្រើប្រាស់ទម្រង់នេះ ទាំងអង្គការ លីកាដូ និងការិយាល័យ នៃឧត្តមស្នងការអង្គការសហប្រជា-ជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា មិនមានស្ថិតិច្បាស់លាស់គ្រប់គ្រាន់លើការលើកឡើងនេះទេ។ ជាក់ស្តែង ចំនួននៃជនជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ នៅតែបន្តកើនឡើង ចាប់តាំងពីមានការបង្កើត ទម្រង់នោះមក។[១៥]

អង្គការ លីកាដូ ជឿជាក់ថា ដោយមានការអប់រំឲ្យបានត្រឹមត្រូវដល់អាជ្ញាធរ អំពីផលប៉ះពាល់អវិជ្ជមាន នៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំ សវនាការ ដោយមិនរើសមុខ ទាំងក្នុង និងក្រៅពន្ធនាគារ នោះការផ្លាស់ប្តូរជាលក្ខណៈប្រព័ន្ធ នឹងអាចកើតមានឡើង។

[១២] Burns Institute, The Evolution of Money Bail Throughout History: http://www.burnsinstitute.org/blog/the-evolution-of-money-bail-throughout-history/.

[១៣] Amnesty International, Courts of Injustice: Suppressing Activism through the Criminal Justice System in Cambodia, 2017, p.19: https://www.amnesty.org/en/documents/asa23/6059/2017/en/.

[១៤] OHCHR, Reforming the pre-trial detention process to prevent arbitrary detention: http://cambodia.ohchr.org/~cambodiaohchr/sites/default/files/2-RLU-SS.pdf.

[១៥] នៅចុងឆ្នាំ២០១៤ មានជនជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ ចំនួន២.៦០០នាក់ នៅចុងឆ្នាំ២០១៦ មានជនជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការចំនួន ៤.០៣៨ នាក់ ហើយនៅចុងឆ្នាំ២០១៧ មានជនជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ ៦.៣៣៧នាក់។ ស្ថិតិទាំងអស់ គឺបានមកពីពន្ធនាគារចំនួន ១៨កន្លែង ដែលត្រូវបានឃ្លាំមើលដោយអង្គការ លីកាដូ។ សំគាល់៖ មិនមានទិន្នន័យគ្រប់គ្រាន់សម្រាប់ឆ្នាំ ២០១៥។

តាមនិយមន័យ ការឃុំខ្លួនគឺជា ការដកហូតនូវសេរីភាពរបស់បុគ្គល។ ច្បាប់ជាតិ និងអន្តរជាតិ បានចែងអំពីការការពារពីការប្រើប្រាស់ការឃុំខ្លួនទៅលើគ្រប់ករណី លើកលែងតែករណី មួយចំនួនដែលចាំបាច់ និងធ្ងន់ធ្ងរខ្លាំង។

មូលដ្ឋានគ្រឹះ នៃប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌទាំងមូល គឺគោលការណ៍សន្មត់ជាមុន ថាគ្មានទោស។ គោលការណ៍នេះ រួមមានរបបនៃការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការ៖ បុគ្គលម្នាក់ គឺត្រូវបានសន្មត់ជាមុនថាគ្មានទោស រហូតដល់តុលាការរកឃើញថាមានកំហុស។ សិទ្ធិនេះត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់អន្តរជាតិដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។[១៦]



បន្ទុកនៃការដាក់ភស្តុតាង និងការជំទាស់ទៅនឹងការសន្មត់ជាមុនថាគ្មានទោស គឺជាតួនាទីរបស់ព្រះរាជអាជ្ញា។[១៧] ច្បាប់កម្ពុជា ក៏បាន តាក់តែងឲ្យមាន ការសន្មត់ជាក់លាក់ជាមុន ថា មានសេរីភាពដោយការអនុវត្តនូវការឃុំខ្លួនបណ្តោះអាសន្ន នៅមុនពេលសវនាការផងដែរ។ នៅខណៈ ដែលការឃុំខ្លួនបណ្តោះអាសន្នរង់ចាំសវនាការអាចជាមធ្យោបាយស្របច្បាប់ នៅក្នុងប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌ ការប្រើប្រាស់មធ្យោបាយនេះ ហួសហេតុ គឺជាអំពើខុសច្បាប់ និងរំលោភបំពានសិទ្ធិរបស់បុគ្គល ក្នុងការដកហូតសេរីភាពរបស់ពួកគេដោយ មិន ចាំបាច់។ ការឃុំខ្លួន ត្រូវតែជាវិធីសាស្ត្រចុងក្រោយ ដោយអាចអនុវត្តបានតែក្នុងករណីដែលមានភាពចាំបាច់បំផុត។

យោងតាមច្បាប់កម្ពុជា កាឃុំខ្លួនបណ្តោះអាសន្ន មុនពេលផ្តន្ទាទោស មានច្រើនទម្រង់ ដូចជា៖

១. បុគ្គលម្នាក់ អាចត្រូវបានតុលាការ ដាក់ឲ្យជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ អំឡុងពេលមានការស៊ើបអង្កេត លើសំណុំរឿងបទល្មើសមជ្ឈិម ឬឧក្រិដ្ឋ ដែលមានទោសពន្ធនាគារចាប់ពីមួយឆ្នាំឡើងទៅ ប្រសិនបើជននោះបំពេញនូវលក្ខខណ្ឌជាក់លាក់មួយ ចំនួនតាមក្រមនីតិវិធីព្រហ្មទណ្ឌ។[១៨] វិធីសាស្ត្រនេះ គឺជាទម្រង់ដែលត្រូវបានតុលាការ ប្រើប្រាស់ច្រើនបំផុត និងមិនចាំបាច់បំផុត នៃការឃុំខ្លួនបណ្តោះអាសន្ន នៅក្នុងប្រទេសកម្ពុជា។ រយៈពេលអតិបរមា កំណត់ដោយច្បាប់មានការប្រែប្រួលទៅតាមស្ថានទម្ងន់ នៃអំពើល្មើស ដែលបានចោទប្រកាន់។[១៩]

២. នៅពេលដែលចៅក្រមស៊ើបសួរ បិទការស៊ើបសួរ ទម្រង់នៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ នឹងត្រូវបញ្ចប់ ប៉ុន្តែចៅក្រមស៊ើបសួរ អាចចេញដីកាថ្មីមួយ ដោយដាក់ជនជាប់ចោទ ឲ្យបន្តជាប់ឃុំបណ្តោះអាសន្ន ចាប់ពីបិទការស៊ើបសួររហូតដល់ថ្ងៃសវនាការ។[២០]

៣. បន្ទាប់ពីសវនាការ ជនជាប់ចោទ អាចនៅតែបន្តជាប់ឃុំខ្លួនបណ្តោះអាសន្នរហូតដល់ថ្ងៃចេញសាលក្រម។[២១]

[១៦] សូមមើលមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា; មាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ; មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[១៧] មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ ការកាត់ទោសជនជាប់ចោទណាម្នាក់ ត្រូវតែរកឲ្យឃើញនូវកំហុសរបស់ជននោះ លើសពីការសង្ស័យធម្មតា ដោយយោងតាមបទដ្ឋាននៃភស្តុតាងតាមក្រមព្រហ្មទណ្ឌកម្ពុជា

[១៨] មាត្រា ២០៤ និង ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[១៩] មាត្រា ២០៨ និង ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[២០] មាត្រា ២៤៩ និង ៣០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[២១] មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

ចៅក្រមស៊ើបសួរ មានសិទ្ធិក្នុងការអនុញ្ញាត ឲ្យជនជាប់ចោទមានសេរីភាព ឬប្រសិនបើ ជននោះនៅជាប់ឃុំបណ្ដោះអាសន្នស្រាប់ អនុញ្ញាតឲ្យដោះលែងជនជាប់ចោទ ឲ្យមានសេរីភាពគ្រប់ពេលវេលា។ សិទ្ធិអំណាចនេះ អាចត្រូវបានចៅក្រមប្រើប្រាស់ ទៅតាមការយល់ឃើញរបស់ខ្លួន ដោយមិនមានតម្រូវការស្នើសុំណាមួយពីជនជាប់ចោទនោះទេ។ ព្រះរាជអាជ្ញា ក៏អាចមានសិទ្ធិស្នើសុំចៅក្រម ឲ្យធ្វើការដោះលែងជនជាប់ចោទណាម្នាក់ ឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន បានដែរ ហើយជនជាប់ចោទ ក៏មានសិទ្ធិក្នុងការស្នើសុំនៅក្រៅឃុំបណ្ដោះអាសន្ន ផងដែរ។ នៅខណៈដែលការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ជួនកាល អាចត្រូវបានផ្ដល់ឲ្យតាមរយៈ ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា ប៉ុន្តែការផ្ដល់ឲ្យនេះ គឺមិនសូវត្រូវបានគេធ្វើឡើង ទៅលើបុគ្គលដែលមានគ្រប់លក្ខខណ្ឌក្នុងការទទួលបាននោះទេ។

មេធាវីការពារជនជាប់ចោទ មានសិទ្ធិ ក្នុងការជំទាស់នឹងអនុសាសន៍ របស់ព្រះរាជអាជ្ញា និង/ឬ បំណងរបស់ចៅក្រមស៊ើបសួរ ក្នុងការដាក់ជនជាប់ចោទឲ្យជាប់ឃុំបណ្ដោះអាសន្ន។ ដោយយោងតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្ន គ្រប់ជនជាប់ចោទទាំងអស់ មានសិទ្ធិក្នុងការទាមទារឲ្យពិនិត្យឡើងវិញជាទៀងទាត់ នូវភាពស្របច្បាប់ នៃការឃុំខ្លួនរបស់អ្នកទាំងនោះ ដែលនឹងត្រូវសម្រេចដោយតុលាការឯករាជ្យ។[២២] ក៏ប៉ុន្តែ ភាពមិនឯករាជ្យនៃប្រព័ន្ធតុលាការនៅកម្ពុជា គឺជាបញ្ហាដ៏ធ្ងន់ធ្ងរ និងត្រូវបានគេចងក្រងទុកយ៉ាងត្រឹមត្រូវ ដែលអាចបណ្ដាលឲ្យមាននូវផលប៉ះពាល់អវិជ្ជមាន ទៅលើសេរីភាពរបស់ជនជាប់ចោទម្នាក់ៗ។[២៣]

រយៈពេលនៃការជាប់ឃុំបណ្ដោះអាសន្ន គឺរយៈពេលដែលរាប់បញ្ចូលក្នុងរយៈពេលទោសពន្ធនាគារ ដែលជនជាប់ចោទ អាចនឹងត្រូវបានតុលាការ ផ្ដន្ទាទោសនៅពេលក្រោយ។[២៤] ក៏ប៉ុន្តែនៅពេលដែលជនជាប់ចោទ ត្រូវបានតុលាការ លើកលែងការចោទប្រកាន់ ហើយប្រសិនបើ នីតិវិធីនៃការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានតុលាការអនុវត្តដោយមិនត្រឹមត្រូវ នោះ ជនជាប់ចោទទាំងនោះ នឹងត្រូវជាប់ក្នុងពន្ធនាគារ ដោយមិនចាំបាច់ និងច្រើនហួសហេតុ។[២៥] លុះត្រាតែការប្រើប្រាស់រយៈពេលអតិបរមា នៃការឃុំខ្លួនបណ្ដោះអាសន្ន មាន



[២២] មាត្រា ២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[២៣] International Bar Association, Justice versus corruption: Challenges to the independence of the judiciary in Cambodia: https://www.ibanet.org/Article/NewDetail.aspx?ArticleUid=fb11e885-5f1d-4c03-9c55-86ff42157ae1.

[២៤] មាត្រា ២០២ និង ៥០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[២៥] នៅ ក្នុងករណីបទល្មើសឧក្រិដ្ឋ គឺរួមទាំងដីកាដាក់ឲ្យឃុំខ្លួនបណ្ដោះអាសន្នរយៈពេល ៦ខែ ដែលអាចត្រូវបានពន្យាពីរដង អំឡុងពេលស៊ើបអង្កេត។ នៅពេលបិទការស៊ើបសួរ ចៅក្រមអាចចេញដីកាដាច់ដោយឡែកមួយទៀត ពន្យាពេលការឃុំខ្លួនជននោះ រហូតដល់ពេលសវនាការរបស់ជននោះ (ដីកាដាច់ដោយឡែកនេះ មានប្រសិទ្ធិភាពសម្រាប់រយៈពេលច្រើនបំផុត ៤ ខែ (មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ))

ភាពចាំបាច់បំផុត (ឧទាហរណ៍ ដើម្បីអនុវត្តសកម្មភាពស៊ើបអង្កេតយ៉ាងចាំបាច់) បើមិនដូច្នោះទេ ការបន្តឃុំខ្លួនបែបនោះ នឹងអាចជាការរំលោភបំពានសិទ្ធិ ក្នុងការទទួលបានការជំនុំជម្រះ នៅក្នុង "វេលាសមស្រប" ឬត្រូវតែដោះលែងជនជាប់ចោទ។[២៦]

ការពន្យាពេលច្រើនហួសហេតុ មុនពេលសវនាការ និងការចេញសាលក្រម ហាក់ដូចជាចាកឆ្ងាយពីមាត្រាមួយចំនួន ដែលតម្រូវឲ្យជនជាប់ឃុំរង់ចាំសវនាការ ត្រូវតែត្រូវបានតុលាការជំនុំជម្រះឲ្យបានកាន់តែឆាប់កាន់តែល្អ នឹងគោរពនូវសិទ្ធិ ក្នុងការការពារក្ដីរបស់បុគ្គលទាំងនោះ។ ប្រសិនបើមានការពន្យាពេល ក្នុងការបញ្ជូនសំណុំរឿងមកជំនុំជម្រះ គឺត្រូវធ្វើការវាយតម្លៃ ទៅលើភាពស្មុគស្មាញនៃរឿងក្ដី។ ការឃុំខ្លួនបណ្ដោះអាសន្ន ដែលមានរយៈពេលយូរ ទៅលើជនជាប់ចោទនៅក្នុងប្រទេសកម្ពុជា គឺរំលោភទៅលើសិទ្ធិ ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយឥតពន្យាពេល។

## ការឃុំខ្លួនបណ្ដោះអាសន្នអំឡុងពេលស៊ើបអង្កេត និងមុនពេលសវនាការ

ជាគោលការណ៍ ជនត្រូវចោទ ត្រូវតែមានសេរីភាព។[២៧] ករណីលើកលែង ដែលចាំបាច់ក្នុងការបង្គាប់ ឲ្យមានការឃុំខ្លួនបណ្ដោះអាសន្នលើជនជាប់ចោទម្នាក់ ដើម្បីធ្វើការស៊ើបអង្កេតហើយជាករណីដែលមានអាទិភាពលើការសន្មត់ជាមុនថា បន្តមានសេរីភាព ត្រូវបានឲ្យនិយមន័យនៅក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[២៨] ប្រសិនបើ ការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ ត្រូវបានយកមកអនុវត្តចៅក្រមត្រូវតែថ្លែងការណ៍ ដោយមានហេតុផល នូវការដកហូតសេរីភាពនេះ ទាំងចំពោះជនត្រូវចោទ និងទាំងនៅក្នុងដីកាបង្គាប់ឲ្យឃុំខ្លួនបណ្ដោះអាសន្នមុនសវនាការ។ យោងតាម គណៈកម្មាធិកាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការត្រូវតែផ្អែកលើការកំណត់នីមួយៗដែលសមហេតុផល និងចាំបាច់ ហើយវាគួរតែជាករណីលើកលែង ជាជាងជាបទដ្ឋានសម្រាប់អនុវត្ត ទូទៅ។[២៩] មាត្រាទាំងនេះក៏អនុវត្ត ទៅលើដីកាឃុំខ្លួនបណ្ដោះអាសន្នជាច្រើន ដែលត្រូវបានចេញ នៅពេលមានការបិទការស៊ើបសួរ ដើម្បីធ្វើការឃុំខ្លួនបុគ្គលណាម្នាក់ រហូតដល់ពេលមានសវនាការលើ ជននោះ។



ទោះជាមានសិទ្ធិ ក្នុងការបង្គាប់ឲ្យឃុំខ្លួន បណ្ដោះអាសន្នរង់ចាំសវនាការ ក៏ដោយក៏ចៅក្រមស៊ើបសួរម្នាក់ មិនចាំបាច់ត្រូវប្រើសិទ្ធិនេះនោះទេហើយចៅក្រមនោះក៏មានសិទ្ធិ ក្នុងការរក្សាសេរីភាព របស់បុគ្គលជាជនជាប់ចោទផងដែរ។ ប្រសិនបើជននោះ កំពុងជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ ស្រាប់ ចៅក្រមមានសិទ្ធិដោះលែងជននោះ នៅគ្រប់ពេលវេលាដោយមិនចាំបាច់ មានការស្នើសុំពីជនជាប់ចោទនោះទេ។ ការដោះលែងជនណាម្នាក់ គួរតែជាការចាំបាច់នៅពេលដែលជននោះ លែងក្លាយជាគ្រោះថ្នាក់ ដោយយោងតាម

[២៦] មាត្រា ១៤(៣)(គ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[១៨] មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ ការកាត់ទោសជនជាប់ចោទណាម្នាក់ ត្រូវតែរកឲ្យឃើញនូវកំហុសរបស់ជននោះ លើសពីការសង្ស័យធម្មតា ដោយយោងតាមបទដ្ឋាននៃភស្តុតាងតាមក្រមព្រហ្មទណ្ឌកម្ពុជា

[២៧] មាត្រា២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

[២៨] ការឃុំខ្លួនបណ្ដោះអាសន្នរង់ចាំសវនាការ អាចត្រូវបានតុលាការបង្គាប់ នៅពេលចាំបាច់ ដើម្បី ១)បញ្ឈប់អំពើល្មើស ឬការពារអំពើល្មើសពីការកើតឡើងវិញម្ដងទៀត ២)ការពារការរំលោភបំពាននានា ទៅលើសាក្សី ឬជនរងគ្រោះ ឬការពារការឃុបឃិតរវាងជនជាប់ចោទ និងជនសមគំនិត ៣)រក្សាភស្តុតាង និងវត្ថុតាង ៤)ធានាវត្តមានរបស់ជនជាប់ចោទអំឡុងពេលនីតិវិធីទៅលើជននោះ ៥)ការពារ សុវត្ថិភាពរបស់ជនជាប់ចោទ ៦) រក្សាសណ្ដាប់ធ្នាប់សាធារណៈ ដើម្បីជៀសវាងការច្របូកច្របល់បង្កឡើងដោយអំពើល្មើស។

[២៩] គណៈកម្មាធិការសិទ្ធិមនុស្ស សេចក្ដីពន្យល់ទូទៅលេខ ៣៥ (២០១៤) កថាខណ្ឌទី៣៨៖ ប្រសិនបើចៅក្រមស៊ើបសួរ ខកខានក្នុងការសំអាងហេតុផល ការឃុំខ្លួនបណ្ដោះអាសន្ន នឹងល្មើសទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាពិសេសមាត្រា ៩(៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលការពារបុគ្គលពីការចាប់ខ្លួន និងឃុំខ្លួនដោយមិនត្រឹមត្រូវ។ ចំពោះបញ្ហានេះ គណៈកម្មាធិការសិទ្ធិមនុស្ស លើកឡើងថា "គំនិតនៃ "ភាពមិនត្រឹមត្រូវតាមច្បាប់" គឺមិនត្រូវស្មើគ្នានឹង "ភាពប្រឆាំងទៅនឹងច្បាប់" ប៉ុន្តែត្រូវតែត្រូវបានបកស្រាយឲ្យទូលាយ ដោយរួមទាំង... ការខ្វះខាតការគិតទុកជាមុន និងការគោរពតាមនីតិវិធីជំនុំជម្រះក្ដីដោយយុត្តិធម៌ ក៏ដូចជាកត្តានៃភាពសមហេតុផល ភាពចាំបាច់ និងភាពសមាមាត្រ"។

លក្ខខណ្ឌមួយចំនួន នៅក្នុងមាត្រា ២០៥។

ព្រះរាជអាជ្ញា ក៏អាចស្នើសុំចៅក្រម ឲ្យធ្វើការដោះលែងជនត្រូវចោទណាម្នាក់ ឲ្យនៅក្រៅឃុំបណ្ដោះអាសន្នបាន ហើយជននោះក៏មានសិទ្ធិ ក្នុងការស្នើសុំតុលាការ ឲ្យដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន បានផងដែរ។ ទោះជានៅពេលករណីខ្លះ ការស្នើសុំឲ្យនៅក្រៅឃុំនោះ ត្រូវបានចៅក្រមផ្ដល់ឲ្យនៅក្នុងប្រព័ន្ធយុត្តិធម៌កម្ពុជា ក៏ការផ្ដល់ឲ្យនោះ នៅតែមិនត្រូវបានផ្ដល់ឲ្យជាជម្រើសដល់ជនដែលមានគ្រប់លក្ខខណ្ឌក្នុងការទទួលបាននោះទេ។ ជនជាប់ឃុំបណ្ដោះអាសន្នរង់ចាំសវនាការ ជាច្រើន ដែលត្រូវបានសម្ភាស ដោយមន្ត្រីស្រាវជ្រាវផ្នែកពន្ធនាគារ របស់អង្គការ លីកាដូ មិនសូវទទួលបានព័ត៌មាន អំពីលទ្ធភាពនៃការដោះលែងឲ្យនៅក្រៅឃុំនោះទេ។ នៅក្នុងឆ្នាំ ២០១៧ មន្ត្រីស្រាវជ្រាវផ្នែកពន្ធនាគារ បានសម្ភាសអ្នកជាប់ពន្ធនាគារ ចំនួន ១.២១១ នាក់។ មានអ្នកជាប់ ពន្ធនាគារចំនួនតែ ១០៥ នាក់ ប៉ុណ្ណោះ (៨,៧ ភាគរយ នៃអ្នកជាប់ឃុំ ដែលត្រូវបានសិក្សា) ដែលបានស្នើសុំនៅក្រៅឃុំ ហើយអ្នកជាប់ឃុំផ្សេងទៀត មិនបានទទួលអត្ថប្រយោជន៍ ពីការសម្រេចចិត្តរបស់តុលាការ ក្នុងការដោះលែង ឲ្យនៅក្រៅឃុំនោះទេ។ ភាគច្រើននៃ ជនជាប់ឃុំ ដែលត្រូវបានសម្ភាស មិនបានស្នើសុំនៅក្រៅឃុំនោះទេ ដោយសារកង្វះខាតព័ត៌មានទទួលបាន ឬកង្វះខាតការយល់ដឹង អំពីសិទ្ធិរបស់អ្នកទាំងនោះ ក្នុងការស្នើសុំនៅក្រៅឃុំបណ្ដោះអាសន្ន។

## ការដាក់ឲ្យស្ថិតនៅក្រោម ការត្រួតពិនិត្យរបស់តុលាការ ជាជម្រើសមួយ

ចៅក្រមជាច្រើន ក៏បានប្រើប្រាស់វិធានការណ៍មួយចំនួនដែលមិនត្រូវការឃុំខ្លួនជនជាប់ចោទ ដើម្បីធានានូវវត្តមានរបស់ជននោះនៅពេលសវនាការ ដោយមិនចាំបាច់ដកហូតសេរីភាព របស់ជននោះ។ ច្បាប់កម្ពុជា បានអនុញ្ញាតឲ្យមានជម្រើសមួយចំនួន ដែលមានលក្ខណៈសមាមាត្រ ច្រើនជាងជម្រើសនៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលអាចរក្សាសេរីភាពរបស់ជនជាប់ចោទ ទោះបីជាសេរីភាពនោះនៅមានលក្ខខណ្ឌ ក៏ដោយ។ មាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឲ្យមានការប្រើប្រាស់ វិធានការណ៍ត្រួតពិនិត្យតាមផ្លូវតុលាការ ទៅលើជនត្រូវចោទ ជាជម្រើសមួយក្រៅពីការឃុំខ្លួនបណ្ដោះអាសន្ន។ យោងតាមមាត្រានេះ ចៅក្រម មានវិធានការណ៍រឹតត្បិត ចំនួន ១២ ប្រភេទ តាមរយៈការត្រួតពិនិត្យរបស់តុលាការ ដែលអាចដាក់ទៅលើជនជាប់ចោទ នៅខណៈដែលអាចរក្សាបាននូវសេរីភាពរបស់ជននោះ។ ចៅក្រម អាចជ្រើសរើសប្រើប្រាស់វិធានការណ៍ មួយ ឬច្រើន ជាជម្រើសផ្សេងពីការឃុំខ្លួនបណ្ដោះអាសន្ន។

## ស្ថិតិចំនួនអ្នកជាប់ពន្ធនាគារបណ្តោះអាសន្នគិតត្រឹម ខែឧសភា ឆ្នាំ២០១៨

| ឈ្មោះពន្ធនាគារ | ចំនួនអ្នកជាប់ឃុំ បណ្តោះអាសន្នរង់ចាំសវនាការ | | | ចំនួនអ្នកជាប់ពន្ធនាគារសរុប | | | ភាគរយអ្នកជាប់ឃុំ បណ្តោះអាសន្នរង់ចាំសវនាការ | | |
|---|---|---|---|---|---|---|---|---|---|
| | ប្រុស | ស្រី | សរុប | ប្រុស | ស្រី | សរុប | %ប្រុស | %ស្រី | %សរុប |
| ពន្ធនាគារPJ | ៤៧ | ២១ | ៦៨ | ២៤៧ | ៤៧ | ២៩៤ | ១៩% | ៤៥% | ២៣% |
| មណ្ឌលកែប្រែ ម១ | ៣.៣១៩ | ០ | ៣.៣១៩ | ៦.៧១១ | ០ | ៦.៧១១ | ៤៩% | ០% | ៤៩% |
| មណ្ឌលកែប្រែ ម២ | ២៨៨ | ៣៣៧ | ៦២៥ | ៥៦១ | ១.០៧១ | ១.៦៤០ | ៥១% | ៣១% | ៣៨% |
| មណ្ឌលកែប្រែ ម៣ | ០ | ០ | ០ | ១.៧២៥ | ០ | ១.៧២៥ | ០% | ០% | ០% |
| មណ្ឌលកែប្រែ ម៤ | ០ | ០ | ០ | ៧០៧ | ០ | ៧០៧ | ០% | ០% | ០% |
| ពន្ធនាគារតាខ្មៅ | ៥៧៩ | ៣១ | ៦១០ | ១.៧៩៦ | ១១៣ | ១.៩០៩ | ៣២% | ២៧% | ៣២% |
| ពន្ធនាគារកំពង់សោម | ៤៨០ | ៣៤ | ៥១៤ | ៨៨៦ | ១០៤ | ៩៩០ | ៥៤% | ៣៣% | ៥២% |
| ពន្ធនាគារកំពង់ស្ពឺ | ២៩២ | ២៣ | ៣១៥ | ៥៩៦ | ៥០ | ៦៤៦ | ៤៩% | ៤៦% | ៤៩% |
| ពន្ធនាគារកំពត | ២៦២ | ១៦ | ២៧៨ | ៧៨៦ | ៣៦ | ៨២២ | ៣៣% | ៤៤% | ៣៤% |
| ពន្ធនាគារកំពង់ឆ្នាំង | ៣៤៧ | ២១ | ៣៦៨ | ៧៥៦ | ៥០ | ៨០៦ | ៤៦% | ៤២% | ៤៦% |
| ពន្ធនាគារកំពង់ចាម | ៦១៤ | ១០៨ | ៧២២ | ១.៦៨៩ | ១៤៥ | ១.៨៣៤ | ៣៦% | ៧៤% | ៣៩% |
| ពន្ធនាគារកំពង់ធំ | ១២១ | ៩ | ១៣០ | ៥២៧ | ៣៦ | ៥៦៣ | ២៣% | ២៥% | ២៣% |
| ពន្ធនាគារកោះកុង | ១១៣ | ១៦ | ១២៩ | ៤៣២ | ៦៤ | ៤៩៦ | ២៦% | ២៥% | ២៦% |
| ពន្ធនាគារពោធិ៍សាត់ | ១៧៩ | ១៦ | ១៩៥ | ៤២៤ | ២៩ | ៤៥៣ | ៤២% | ៥៥% | ៤៣% |
| ពន្ធនាគារបាត់ដំបង | ៣៩៣ | ៣៨ | ៤៣១ | ១.៦៣១ | ១១៧ | ១.៧៤៨ | ២៤% | ៣២% | ២៥% |
| ពន្ធនាគារបន្ទាយមានជ័យ | ៤៥៨ | ៤១ | ៤៩៩ | ១.៣១៨ | ១២៦ | ១.៤៤៤ | ៣៥% | ៣៣% | ៣៥% |
| ពន្ធនាគារសៀមរាប | ១.០៩៣ | ៩៣ | ១.១៨៦ | ២.៥១១ | ២១៥ | ២.៧២៦ | ៤៤% | ៤៣% | ៤៤% |
| ពន្ធនាគារស្វាយរៀង | ១២៥ | ១៣ | ១៣៨ | ៣៨០ | ៣២ | ៤១២ | ៣៣% | ៤១% | ៣៣% |
| **សរុប** | **៨.៧១០** | **៨១៧** | **៩.៥២៧** | **២៣.៦៨៣** | **២.២៤៣** | **២៥.៩២៦** | **៣៧%** | **៣៦%** | **៣៧%** |

សំគាល់៖ តារាងនេះបង្ហាញតែទិន្នន័យ នៃចំនួនជនជាប់ចោទ និងជនត្រូវចោទ ដែលកំពុងជាប់ឃុំឃាំង ប៉ុន្តែមិនទាន់ចូលខ្លួនជំនុំជម្រះក្តី ដែលរួមមាន អ្នកជាប់ឃុំបណ្តោះអាសន្នរង់ចាំសវនាការ។

## អនុសាសន៍របស់អង្គការ លីកាដូ៖

- សូមធានាថា ជនដែលមានសិទ្ធិ គួរតែត្រូវបានតុលាការសាកសួរ ប្រសិនបើពួកគេចង់ស្នើសុំនៅក្រៅឃុំ ជាពិសេសចំពោះករណីជនដែលងាយរងគ្រោះមួយ ចំនួន ដូចជាស្ត្រីមានកូនតូច និងជនជាប់ឃុំជាអនីតិជន។

- សូមធានាថា ការឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានតុលាការអនុវត្តឲ្យបានត្រឹមត្រូវ និងគួរតែជាមធ្យោបាយចុងក្រោយ ដោយយោងតាមគោលការណ៍សន្មត់ជាមុនថាគ្មានទោស។

- សូមធានាថា នឹងមានការពិចារណាត្រឹមត្រូវ ដោយយោងតាមការការពារនៃច្បាប់ ទៅលើស្ថានភាពផ្ទាល់ខ្លួនមួយចំនួនរបស់ជនជាប់ចោទ ជាពិសេសករណីរបស់ពលរដ្ឋដែលងាយរងគ្រោះមួយចំនួន ដូចជាស្ត្រីមានផ្ទៃពោះ និងម្តាយរបស់កុមារតូចៗ ហើយនិងជនជាប់ឃុំជាអនីតិជន មុនពេលសម្រេចចេញដីកាបង្គាប់ឲ្យឃុំខ្លួន។

- សូមធានាថា ទម្រង់នៃការឃុំខ្លួន ឆ្នាំ ២០១៤ ត្រូវបានតុលាការប្រើប្រាស់ដោយត្រឹមត្រូវ ដោយពន្យល់ឲ្យបានច្បាស់លាស់នូវមូលហេតុមួយក្នុងចំណោមមូលហេតុទាំង ៦ ដែលនាំឲ្យមានការឃុំខ្លួនលើករណីណាមួយ ហើយត្រូវមានអំណះអំណាងឲ្យបានច្បាស់លាស់ដើម្បីធ្វើការសម្រេចចិត្តបង្គាប់ឲ្យឃុំខ្លួន។

- សូមធានាថា គ្រប់ជនជាប់ចោទទាំងអស់ ទទួលបានសិទ្ធិមួយចំនួនមុនពេលមានសវនាការជំនុំជម្រះ និងទទួលបានការការពារមួយចំនួនផងដែរ ដែលរួមមាន សិទ្ធិក្នុងការទទួលបានមេធាវី សិទ្ធិក្នុងការទទួលបានការជូនដំណឹងអំពីបទចោទទៅលើអ្នកទាំងនោះ និងការយល់ដឹងអំពីនីតិវិធីនានាពាក់ព័ន្ធនឹងការអនុវត្ត និងការផ្តល់នូវការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ន ហើយនិងលទ្ធភាពក្នុងការស្នើសុំនៅក្រៅឃុំ ជាពិសេសនៅក្នុងករណីជនជាប់ចោទជាជនងាយរងគ្រោះ ដូចជាជនជាប់ឃុំជាអនីតិជន ស្ត្រីមានផ្ទៃពោះ និងម្តាយរស់នៅជាមួយកូនតូច។ នីតិវិធីនេះ គួរត្រូវបានតុលាការពន្យល់ឲ្យបានច្បាស់លាស់ និងអនុវត្តឲ្យបានទាន់ពេលវេលា។

- សូមដាក់អាទិភាព ទៅលើសវនាការជំនុំជម្រះលើបណ្តឹងសុំនៅក្រៅឃុំរបស់ជនជាប់ឃុំដែលងាយរងគ្រោះ ដូចជាស្ត្រីមានផ្ទៃពោះ និងម្តាយរស់នៅ ជាមួយកូនតូច ជនជាប់ឃុំជាអនីតិជន និងអ្នកការពារសិទ្ធិមនុស្ស។ ដូចនេះពួកគេ នឹងមិនចាំបាច់ជាប់ឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេលយូរ និងមិនមានកំណត់ពេលវេលានោះទេ។

- សូមធានាថា ការធានាឲ្យនៅក្រៅឃុំបណ្តោះអាសន្ន គួរតែត្រូវបានកំណត់ក្នុងតម្លៃជាទឹកប្រាក់សមរម្យ ដោយពិចារណាទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ជនជាប់ចោទ។

- សូមធានាថា ប្រាក់តំកល់ធានានៅក្រៅឃុំ ដែលត្រូវបានដាក់ដើម្បីធានា គួរត្រូវបានប្រគល់ឲ្យវិញនៅពេលបញ្ចប់នីតិវិធីនានា ទោះជាលទ្ធផលនៃនីតិវិធីជាការផ្តន្ទាទោសដាក់ពន្ធនាគារ ឬក៏រកឃើញថាគ្មានកំហុសនៅពេលចេញសាលក្រម។

www.licadho-cambodia.org